ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



**Work Activities**

ប្រចាំខែមីនា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃឃោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ | ៣ |
| ៣- | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា | ៥ |
| ៤- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០១៣ | ៧ |
| ៥- | សកម្មភាពផ្សេងទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# បែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍

ឯកឧត្តម **គាំង តុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ បានដឹកនាំអង្គប្រជុំដែលមានរយៈពេល៤ថ្ងៃគឺចាប់ផ្តើមនៅថ្ងៃទី២៤ ខែតុលា ហើយបញ្ចប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការពារជាតិ។



យោងតាមមាត្រា៣៩ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ បានចែងថា បែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពដែលមានចែងក្នុងចំណុច ១,២,៣,៤,៥ នៃមាត្រា៣៨ ព្រមទាំងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។ ដូច្នេះ ដើម្បីដំណើរការអនុវត្តច្បាប់នេះឲ្យមានភាពរលូន និងការរៀបចំកងយោធពលខេមរភូមិន្ទឲ្យកាន់តែមានលក្ខណៈគ្រប់គ្រាន់និងមានប្រសិទ្ធភាព ក្រសួងការពារជាតិបានរៀបចំអនុក្រឹត្យនេះ ដើម្បីបង្កើតនីត្យានុកូលភាពក្នុងដំណើរការរបស់កងយោធពលខេមរភូមិន្ទឲ្យកាន់តែប្រសើរឡើង និង មានគោលបំណងដូចខាងក្រោម៖

-រៀបចំកងយោធពលខេមរភូមិន្ទតាមទម្រង់នៃច្បាប់ ដើម្បីផ្តល់លក្ខណៈងាយស្រួលដល់ការគ្រប់គ្រងការគោរពតួនាទីនិងភារកិច្ចរបស់ខ្លួន។



-ធានាដល់សិទ្ធិ សេរីភាព និងអត្ថប្រយោជន៍សម្រាប់កងយោធពលខេមរភូមិន្ទ។

-កំណត់លក្ខណៈសម្បត្តិ ឋានន្តរស័ក្តិ សិទ្ធិឈប់សម្រាក សិទ្ធិទទួលប្រាក់បៀវត្ស សិទ្ធិចូលនិវត្តន៍ និងបាត់បង់សមត្ថភាពការងារ និងគុណប្រយោជន៍សម្រាប់នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

## សេចក្តីព្រាងច្បាប់ស្តីពី

# វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ហុង ថា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ទេស សំអុន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងយុត្តិធម៌។



ក្រសួងយុត្តិធម៌បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានហេតុផលដូចខាងក្រោម៖

១-ជាគោលការណ៍ច្បាប់ វត្ថុតាងរួមទាំងផលនៃបទល្មើស ក៏ជាកម្មវត្ថុនៃការរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋ។ នៅក្នុងបទល្មើសព្រៃឈើ គឺឈើដែលជាកម្មវត្ថុនៃបទល្មើសព្រៃឈើ រួមទាំងសម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋចំពោះបទល្មើសព្រៃឈើថ្នាក់លេខ១និងបទល្មើសព្រៃឈើថ្នាក់លេខ២ នឹងអាចជាកម្មវត្ថុនៃការរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋចំពោះបទល្មើសព្រៃឈើថ្នាក់លេខ៣(មាត្រ៩៣ នៃច្បាប់ស្តីពីព្រៃឈើ)។ យោងតាមមាត្រាទី៨២ នៃច្បាប់ស្តីពីព្រៃឈើ បានចែងថា មន្ត្រីរដ្ឋបាលព្រៃឈើត្រូវឃាត់ទុកជាវត្ថុតាងនៃបទល្មើសព្រៃឈើរហូតដល់សំណុំរឿងនៃបទល្មើសព្រៃឈើត្រូវបានដោះស្រាយរួចជាស្ថាពរ តាមរយៈការបង់ពិន័យអន្តរការណ៍ ឬ

តាមការជំនុំជម្រះរបស់តុលាការ។ ការរឹបអូសវត្ថុតាងនៃបទល្មើសព្រៃឈើជាទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវធ្វើតាមរយៈសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

២-កន្លងមកការរឹបអូសវត្ថុតាងនៃបទល្មើសព្រៃឈើជាទ្រព្យសម្បត្តិរបស់រដ្ឋ មិនមានឧបសគ្គផ្នែកនីតិវិធីច្បាប់នោះទេ ប្រសិនបើជនល្មើសត្រូវបានចាប់ខ្លួន ឬត្រូវបានស្គាល់អត្តសញ្ញាណ។ ប៉ុន្តែ បញ្ហាផ្នែកនីតិវិធីដែលកើតមានកន្លងមក គឺក្នុងករណីដែលត្រូវរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋនូវវត្ថុតាងជាសម្ភារៈបរិក្ខារនិងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសព្រៃឈើ ហើយជនប្រព្រឹត្តបទល្មើសគឺជាអញ្ញាត្រជន(មានន័យថា ជនល្មើសមិនត្រូវបានស្គាល់អត្តសញ្ញាណ)។ បញ្ហាដែលធ្វើឲ្យមានភាពស្មុគស្មាញ គឺនៅពេលដែលបង្ក្រាបបទល្មើសព្រៃឈើ ជនល្មើស ក៏ដូចជាអ្នកពាក់ព័ន្ធនៅក្នុងបទល្មើស មិនត្រូវបានស្គាល់អត្តសញ្ញាណដោយសារមិនត្រូវបានចាប់ខ្លួន ហើយរថយន្តទៀតសោតដែលជាមធ្យោបាយដឹកជញ្ជូនឈើខុសច្បាប់ក៏មិនមានស្លាកលេខសម្គាល់ ឬក៏មិនមានចុះបញ្ជីត្រឹមត្រូវ ជាបញ្ហាដែលមិនអាចស្រាវជ្រាវរកអ្នកពាក់ព័ន្ធឃើញ។ យោងតាមក្រមនីតិវិធី ជាពិសេសមាត្រា២៤៧ ចៅក្រមស៊ើបសួរមិនអាចសម្រេចបញ្ជូនរឿងទៅជំនុំជម្រះបានទេ ក្នុងករណីដែលជនល្មើសណាម្នាក់មិនត្រូវបានស្គាល់អត្តសញ្ញាណក្រោយពីការស៊ើបសួរ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងការចោទប្រកាន់ ហើយសំណុំរឿងមិនអាចត្រូវបញ្ជូនទៅតុលាការ ដើម្បីជំនុំជម្រះចេញជាសាលក្រម ឬសាលដីកាស្ថាពរឡើយ ដែលជាឧបសគ្គផ្នែកនីតិវិធីក្នុងការសម្រេចរឹបអូសយានយន្តដែលប្រើប្រាស់ប្រព្រឹត្តបទល្មើស ហើយដែលយានយន្តទាំងនេះមិនមានស្លាកលេខសម្គាល់ ឬមិនមានចុះបញ្ជីត្រឹមត្រូវ។ ដោយឡែក ចំពោះផល និងអនុផលព្រៃឈើ ទោះបីជាជនល្មើសមិនត្រូវបានស្គាល់អត្តសញ្ញាណក៏ដោយ ក៏ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចប្រគល់ទៅឲ្យរដ្ឋបាលព្រៃឈើចាត់ចែងតាមនីតិវិធីដូចសាលក្រម ឬសាលដីកាស្ថាពរ របស់តុលាការផងដែរ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ហើយបានកត់សម្គាល់ឃើញថា ការស្នើសុំវិសោធនកម្មមាត្រាទាំង៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាដូចបានរៀបរាប់ខាងលើ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

## សេចក្តីព្រាងគោលនយោបាយជាតិស្តីពី

# ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

កាលពីថ្ងៃទី២០ និងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងគោលនយោបាយជាតិស្តីពី **ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា គឺជាទស្សនៈវិស័យថ្មីតម្រង់ទិសវិស័យកីឡាជាតិ ឈានទៅរកការធ្វើទំនើបកម្ម ដើម្បីសុខមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប និងដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គម ស្របគោលនយោបាយកាត់បន្ថយភាពក្រីក្រ។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យអប់រំកាយនិងកីឡា ដោយបានចាត់តាំងគ្រប់រូបភាពតាមលទ្ធភាពតាំងពីមូលដ្ឋាន រហូតដល់ថ្នាក់ជាតិ បំផុសឲ្យប្រជាពលរដ្ឋលេងកីឡា ដើម្បីលើកកម្ពស់សុខុមាលភាព ផ្លូវកាយ និងផ្លូវចិត្ត រួមចំណែកការពារ និងកសាងប្រទេសជាតិឡើងវិញ។ ការហ្វឹកហាត់អប់រំកាយនិងកីឡា គឺជាសិទ្ធិមូលដ្ឋានសម្រាប់ទាំងអស់គ្នា។ ជាទូទៅការអប់រំកាយ និងកីឡា ជាធាតុសំខាន់នៃការអប់រំពេញមួយជីវិតនៅក្នុងប្រព័ន្ធអប់រំ។

ដើម្បីជំរុញអនុវត្តគោលនយោបាយកំណែទម្រង់វិស័យអប់រំ ដែលឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ គោលដៅអភិវឌ្ឍសហសវត្សកម្ពុជា ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០០៩-២០១៣ និងឯកសារអន្តរជាតិពាក់ព័ន្ធនានាឲ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា សំដៅធ្វើឲ្យយុវជននិងពលរដ្ឋកម្ពុជាទទួលបាននូវឱកាសនៃការអប់រំ ដោយហេតុថាការអប់រំកាយ និងកីឡាជាសមាសភាគមួយនៃវិស័យអប់រំ ដែលជាមធ្យោបាយហាត់ពត់រាងកាយ និងបញ្ញាស្មារតីរបស់មនុស្សឲ្យមានការលូតលាស់ល្អ រក្សាកម្លាំងពលំមាំមួន និងមានសុខភាពល្អ ជួយកសាងធនធានមនុស្សឲ្យក្លាយជាពលរដ្ឋល្អ និងកំណត់បានពីការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងគោលនយោបាយនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។




(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកុម្ភៈ ឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,២% ធៀបនឹងខែមុន និងកើនឡើង ១,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | |
|---|---|---|
| *ក្រុមទំនិញ* | *មុខទំនិញ* | |
| ម្ហូបអាហារ : +២,០% | អង្ករ : +១,៧% | ឧស្ម័ន: +១,៧% |
| សម្លៀកបំពាក់ និងស្បែកជើង : +៣,៧% | សាច់គោស្រស់: +១៥% | ប្រេងសាំង: +១,៥% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : +១,៨% | សាច់មាន់ស្រស់: +២,៦% | ប្រេងម៉ាស៊ូត: +០,៧%។ |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : +១,៨% | ត្រីស្រស់ : +១,៦% | |
| ការដឹកជញ្ជូន: -០,២% | បន្លែ: +៥,៨% | |
| ភោជនីយដ្ឋាន: +៣,៤% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១-២០១៣

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា^P | មេសា^P | ឧសភា P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | *១,៤%* | *១,៩%* | *១,៨%* | | | | | | | | - |
| | ខែមុន | ០,៣% | ០,២% | *០,៣%* | *១,០%* | *-១,២%* | | | | | | | | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |

P: តួលេខខែកុម្ភៈ **មីនា** និង**មេសា** ឆ្នាំ២០១៣ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ **DECOMPOSITION)**

ក្រាហ្វ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១២ និង២០១៣ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




➡**អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | អត្រាខែកុម្ភៈ ២០១៣ | អត្រាខែមករា ២០១៣ | អត្រាខែកុម្ភៈ ២០១២ | *ប្រភេទ* | អត្រាខែកុម្ភៈ ២០១៣ | អត្រាខែមករា ២០១៣ | អត្រាខែកុម្ភៈ ២០១២ |
|---|---|---|---|---|---|---|---|
| ៛/ដុល្លារ | ៣៩៩៥៛/១$ | ៣៩៩៥៛/១$ | ៤០១៥៛/១$ | បាត/ដុល្លារ | ២៩,៨៣បាត/១$ | ២៩,៧២បាត/១$ | ៣០,៣៣បាត/១$ |
| ៛/បាត | ១៣៤៛/១បាត | ១៣៤៛/១បាត | ១៣២៛/១បាត | ដុង/ដុល្លារ | ២០៨៩០ដុង/១$ | ២០៨០៥ដុង/១$ | ២០៨២០ដុង/១$ |
| ៛/ដុង | ០,១៩១៛/១ដុង | ០,១៩២៛/១ដុង | ០,១៩២៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

- *ចំណូលថវិកាជាតិអនុវត្តបានចំនួន ៦២៣,៩ ពាន់លានរៀល (មធ្យមប្រចាំខែ ៥៨% នៃគម្រោង) ក្នុងនោះ:* ចំណូលចរន្តចំនួន ៦១៨,០ ពាន់លានរៀល (មធ្យមប្រចាំខែ ៨១% នៃគម្រោង) និងមិនមានចំណូលមូលធនទេក្នុងខែកុម្ភៈនេះ។
- បើធៀបនឹងខែមុនចំណូលថវិកាជាតិ កើនឡើង ១៩% និងកើនឡើង ១% *ធៀបនឹងខែដូចគ្នាឆ្នាំមុន* ។ គួរកត់សម្គាល់ថា ចំណូលចរន្តខែកុម្ភៈ ឆ្នាំ២០១៣ និងឆ្នាំ២០១២ មានចំនួនប្រហាក់ប្រហែលគ្នា។
- នៅក្នុងចំណូលចរន្ត៖

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១២ និង ២០១៣
(ពាន់លានរៀល)



✓ ចំណូលសារពើពន្ធមានចំនួន ៥១០,៦ ពាន់លានរៀល កើនឡើង ៧,២% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ១០៧,៤ ពាន់លានរៀល កើនឡើង ១១៦% ធៀបនឹងខែមុន ប៉ុន្តែ ថយចុះ ៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : -១២% | (-៤%) | ➢ នេសាទ: +៣៩៨% | (-៧៤%) |
| ➢ ចំណូលពន្ធដារ : +១១% | (+៣៣%) | ➢ រុក្ខាប្រមាញ់ : — | (-៧៦%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +៦២% | (+១៨%) | ➢ អាកាសចរណ៍ស៊ីវិល : -៩៩% | (-១០០%) |
| ✧ កាស៊ីណូ : +៨២% | (+៥៩%) | ➢ ផលទុនទេសចរណ៍ : -៧៧% | (-៨៨%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +២% | (-៨១%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +១២០% | (+១៦២%) |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +៤៨% | (+១%) | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): -៩៩% | (-៩៩%) |

↳ ***ចំណាយថវិកាជាតិ*** អនុវត្តបានចំនួន ២៨៦ ពាន់លានរៀល ( *មធ្យមប្រចាំខែ ២៤% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ២២៨ ពាន់លានរៀល ( *មធ្យមប្រចាំខែ ៣៣% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៥៨ ពាន់លានរៀល។

↳ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ៥០% និងកើនឡើង ២៣៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តកើនឡើង ៣២% ធៀបនឹងខែមុន និងកើនឡើង ១៦៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳ *ថវិកាជាតិនៃខែកុម្ភៈមាន**អតិរេក ៣៣៨** ពាន់លានរៀល ស្មើនឹង ៨៤,៥ លានដុល្លារ ស.រ.អា* ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ មានលក្ខណៈដូចខាងក្រោម៖

↳ រូបិយវត្ថុ $M_2$ មានចំនួន ២៩៨៣១ ពាន់លានរៀល កើនឡើង ១,៧% ធៀបនឹងខែមុន និងកើនឡើង ២០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ កំណើន $M_2$ ធៀបនឹងខែមុន បណ្តាលមកពីរូបិយវត្ថុក្រៅធនាគារ កើនឡើង ៣% ប្រាក់បញ្ញើចរន្តកើនឡើង ១៦,៩% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ១,៦%។

↳ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារ** មានចំនួន ១៧,៣% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨២,៧%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែកុម្ភៈ ឆ្នាំ២០១៣



| សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៧,២% | ១៧,៣% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៧% | ១៣,៧% | | | | | | | | | | |

បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែកុម្ភៈ២០១៣: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




- ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធមានចំនួន ៣៧៧៤ លានដុល្លារ កើនឡើង ៨,៦% ធៀបនឹងខែមុន និងកើនឡើង ២០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងខែនេះមានចំនួន ៩៨០៨ ពាន់លានរៀល កើនឡើង ០,៤% ធៀបនឹងខែមុន និងកើនឡើង ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- *ការផ្តល់ឥណទាន៖*

| ផ្តល់ដោយ | កុម្ភៈ ២០១៣ | មករា ២០១៣ | កុម្ភៈ ២០១២ |
|---|---|---|---|
| ធនាគារពាណិជ្ជ (ពាន់លានរៀល) | ២៤១៧៥ | ២៣៩៣០ | ១៨៤៤៤ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ពាន់លានរៀល) | មិនទាន់មានតួលេខ | ៣៧១៦ | ២៨០៤ |

- *អត្រាការប្រាក់ប្រចាំឆ្នាំ* នៅធនាគាពាណិជ្ជនាខែកុម្ភៈ៖

| ប្រភេទអត្រាការប្រាក់ | កុម្ភៈ ២០១៣ | មករា ២០១៣ | កុម្ភៈ ២០១២ |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៩៤% | ៦,៣៤% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៧៨% | ១៦,៩៣% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤៥% | ៤,៤៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៨៥% | ១៣,៥៤% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតផលនេសាទមានចំនួន៤០,៥ពាន់តោន ថយចុះ ១១% ធៀបនឹងខែមុន និងថយចុះ៥៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- **ឧស្សាហកម្ម៖**
  - ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា (មិនទាន់មានតួលេខ)
    - ⇨ វារីអគ្គិសនី (មិនទាន់មានតួលេខ)

- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៩០ លានដុល្លារ ថយចុះ ១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន—កុម្ភៈ ២០១៣ | ចំនួន—មករា ២០១៣ | ចំនួន—កុម្ភៈ ២០១២ |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ១១ | ១៥ | ៧ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ៩៣៤ | ៩២៣ | ៧១៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៦ | ១០ | ១៩ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៩ | ១៤ | ១០ |

**សំណង់** (ការអនុញ្ញាត)៖

- ✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤៥២ ពាន់ម² កើនឡើង ៨% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៣៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១១៧ លានដុល្លារ ថយចុះ ៧% ធៀបនឹងខែមុន និងថយចុះ ៤៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម² —កុម្ភៈ ២០១៣ | ពាន់ម² —មករា២០១៣ | ពាន់ម² —កុម្ភៈ ២០១២ |
|---|---|---|---|
| ▪ លំនៅឋាន | ១០៥,៤ | ១៤៤,២ | ២៤១,៩ |
| ▪ ឧស្សាហកម្ម | ១៧៩,០ | ៩០,៦ | ២៦៩,៩ |
| ▪ ទេសចរណ៍ | ៤៥,៧ | ២១,២ | ១៩៤,០ |
| ... | | | |
| អនុញ្ញាតសរុប | ៤៥២ | ៤២០ | ៧៤២ |

- ✓ សំណង់ដែលពេញនិយមនាខែនេះគឺ ឧស្សាហកម្ម (៤០% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) លំនៅឋាន (២៣% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងទេសចរណ៍ ១០%។

**ការងារ៖**

| ប្រភេទ | នាក់—កុម្ភៈ២០១៣ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៧៦៤ | -១១% | -១១% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៦៣១ | -១៧% | -៦០% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១១២៨ | -១៥% | -៧៨% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៥០៣ | -១៨% | +១០% |

**វិនិយោគ៖**

- ✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)៖

| ប្រភេទ | កុម្ភៈ២០១៣ | មករា២០១៣ | កុម្ភៈ២០១២ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១២២ | ៦៣ | ១៤៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៩ | ០ | ២៨ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៨២ (-) | ៦៣ (-) | ១១៦ (៣) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២១ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៩ | ១៤ | ១៦ |
| បង្កើតការងារ (ពាន់នាក់) | ២៧ | ២៦ | ៣២ |

**សេវាកម្ម និងទេសចរណ៍៖**

✓ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន—កុម្ភៈ២០១៣ | ចំនួន— មករា២០១៣ | ចំនួន—កុម្ភៈ២០១២ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២២១ | ១៥៣ | ២៧៤ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ០ | ៣ | ១ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៩០ | ១៣០ | ១៧៨ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៣៥៨ពាន់តោន ថយចុះ ២៤% ធៀបនឹងខែមុន និង ថយចុះ១៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: -១៣% | (-១២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +៧៥% | (+៣៩%) |
| ▪ កំពង់ផែកំពង់សោម: -២% | (+២៤%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៣០% | (+១៥%) |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៦ | +១៩% | -១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | មិនទាន់មានតួលេខ | — | — |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | — | — |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | មិនទាន់មានតួលេខ | — | — |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | មិនទាន់មានតួលេខ | — | — |
| ✓ តាមផ្លូវអាកាស | មិនទាន់មានតួលេខ | — | — |
| ✓ តាមផ្លូវគោក និងទឹក | មិនទាន់មានតួលេខ | — | — |

## ៥) ស្ថានភាពវិស័យពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែកុម្ភៈមានចំនួន ២៨០១ ពាន់លានរៀល (ស្មើនឹង ៧០០ លានដុល្លារ ស.រ.អា.) ថយចុះ១៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១៦% | +២៤% | ដែកសំណង់ | -៥៣% | +៨% |
| ប្រេងម៉ាស៊ូត | -១៦% | -១៥% | ស៊ីម៉ង់ត៍ | -៨% | -១០% |
| ឧស្ម័ន | +៧% | -៤៦% | គ្រឿងអេឡិចត្រូនិក | -២៣% | -៣២% |
| រថយន្តសរុប (ព.ល.រ) | +១៥% | +៨% | ម៉ូតូ (គ្រឿង) | -១២% | +១២៣% |
| រថយន្តសរុប (គ្រឿង) | -២% | ០ | អង្ករ | -៩៣% | +៥៣% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៤៤% | +២៧៥% | ជី និងថ្នាំកសិកម្ម | -២១% | -១៧% |
| ផ្លែឈើ និងបន្លែ | ០ | +៣៥% | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -២៩% | +២៩% |

➡ **ការនាំចេញ** ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ មានចំនួន ១៧២៤ ពាន់លានរៀល ស្មើនឹង ៤៣១ លានដុល្លារ ស.រ.អា. (៦២% នៃការនាំចូល) ថយចុះ ២៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមានៈ

| ទំនិញ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៩៧% | -៩៨% | ផលិតផលនេសាទ | -១៣% | -៦៣% |
| វាយនភណ្ឌនិងស្បែកជើង | -២៤% | +៣% | កៅស៊ូ | -៤៦% | -៣១% |
| អង្ករ | -១២% | +៦៥% | | | |

➡ ក្នុងខែកុម្ភៈនេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១០៧៦ ពាន់លានរៀល ស្មើនឹង ២៦៩ លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈ ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោមៈ

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +០,៤% | +១៥% | បញ្ហាតម្រូវការ និងការផ្គត់ផ្គង់ |
| ២ | ផលិតកម្មនេសាទ | -១១% | -៥៥% | — |
| ៣ | ទំនិញដឹកជញ្ជូនតាមផែ | -២៤% | -១៨% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោមៈ*

ការអនុវត្តចំណូលថវិកាជាតិសម្រាប់ពីរខែដើមឆ្នាំ២០១៣ មានកម្រិតទាបជាងរយៈពេលដូចគ្នាឆ្នាំ២០១២ ចំនួន ២% ដោយសារមានការថយចុះនៃចំណូលពន្ធ និងអាករគយ។ រីឯចំណាយថវិកាជាតិនាដើមឆ្នាំ តែងតែមានការយឺតយ៉ាវ។

*សេចក្តីសន្និដ្ឋានៈ*

*ក)* តួលេខវិនិយោគក្នុងពីរខែដើមឆ្នាំនេះមានចំនួន ១៨៥ លានដុល្លារប៉ុណ្ណោះ ថយចុះប្រហែល ៥០% បើធៀបនឹងរយៈពេល២ខែដូចគ្នាឆ្នាំ២០១២ ។ រីឯវិស័យសំណង់ តួលេខតម្លៃអនុញ្ញាតឲ្យសាងសង់ ក៏មានការថយចុះ ១៤% ដែរ ។ នេះជាសញ្ញាគួរឲ្យយកចិត្តទុកដាក់សម្រាប់ការចាប់ផ្តើមនៃសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៣។

*ខ)* ការឡើងថ្លៃសាច់គោគឺជាបញ្ហាគួរឲ្យយកចិត្តទុកដាក់បំផុត។ បច្ចុប្បន្ននៅកម្ពុជាគោ និងក្របីលែងដើរតួសំខាន់សម្រាប់កសិកម្មទៀតទេ។ រីឯកម្លាំងពលកម្មជនបទមួយចំនួនធំបានងាកមកបម្រើវិស័យកម្មន្តសាលវិញ នាំឲ្យការចិញ្ចឹមលក្ខណៈគ្រួសារមានការថយចុះ។ គួរមានយុទ្ធសាស្ត្រជំរុញការចិញ្ចឹមគោជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី
## ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែមីនា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៣/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការ អភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មា ធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ០៣/០៣/១៣ ម៉ោង ០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាលសន្និសីទចតុមុខ។ |
| ៣ | ០៤/០៣/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី១៧ និងគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី១៤ ជូនដល់គរុនិស្សិត និងគរុសិស្ស នៃវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៤ | ០៤/០៣/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច។<br>២-សេចក្តីព្រាងសារាចរ និងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាន នៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/០៣/១៣<br>ម៉ោង ១០:៣០នាទី | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យឯកឧត្តម Patrick Devedjian តំណាងរាស្ត្រ និងជាប្រធានក្រុមប្រឹក្សាខេត្ត Hauts-de-Seine ចូលជួបពិភាក្សាការងារ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៥/០៣/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច។<br>២-សេចក្តីព្រាងសារាចរ និងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាន នៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៧/០៣/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រដល់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ស្ថិរភាពសង្គម សិស្សមន្ត្រីក្រមការជំនាន់សមធម៌សង្គម និងប្រគល់វិញ្ញាបនបត្រដល់កម្មសិក្សាការីឆ្នាំ២០១១-២០១២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៣ របស់សាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៨ | ០៨/០៣/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី១០២ ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ "សិទ្ធិស្មើគ្នា ឱកាសដូចគ្នា ដើម្បីពន្លឿនកិច្ចអភិវឌ្ឍន៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | ១១/០៣/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រ ជូនដល់សិក្ខាកាម និងនិស្សិតនៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១០ | ១២/០៣/១៣<br>ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ឃឹម ណុលសន** និងលោក **ម៉ក់ ឆារ៉ា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១២/០៣/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ នៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃឃោធិនអាជីព និងបទប្បញ្ញត្តិដោយឡែក ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃអចលនទ្រព្យ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៣/០៣/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និង មាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៤/០៣/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះខណ្ឌសីមា និងឆ្លងសមិទ្ធផលនានា នៅវត្តនន្ទមុនី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី
## ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែមីនា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ១៤/០៣/១៣ ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និង មាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ នៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃឃោធិនអាជីព និងបទប្បញ្ញត្តិដោយឡែក ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។ ៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ១៥/០៣/១៣ ម៉ោង ១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីបើកឯកសារដេញថ្លៃ (១)លើការងារសាងសង់ផ្លូវចំណតរថយន្ត និងប្រឡាយរំដោះទឹកនៅ Pavis ខាងលិចប្រាសាទតាព្រហ្ម និង (២)លើការងារជួសជុលផ្លូវរាងខាងត្បូងក្រុងសៀមរាប ដោយស្រោចកៅស៊ូ DBST ២ស្រទាប់លើកំណាត់ផ្លូវប្រវែងសរុប ៣,០១៥ គីឡូម៉ែត្រ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ១៦-១៧/០៣/១៣ | ចូលរួមមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស នៅមជ្ឈមណ្ឌល សន្និបាត និងពិព័រណ៍កោះពេជ្រ (សាលមហោស្រព)។ |
| ១៧ | ១៨/០៣/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកសន្និបាតអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១១-២០១២ និងលើកទិសដៅឆ្នាំសិក្សា២០១២-២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និង ជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ច នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (TECHNO)។ |
| ១៨ | ១៩/០៣/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាល និងចែកបណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ក្នុងឃុំសំរោង និងឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ។ |
| ១៩ | ២០/០៣/១៣ ម៉ោង ១៥:០០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប។ |
| ២០ | ២១/០៣/១៣ ម៉ោង ០៩:៣០នាទី | ចូលរួមក្នុងពិធីបើកជាផ្លូវការនូវការពង្រីកអគារ នៃអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប នៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប។ |
| ២១ | ២២/០៣/១៣ ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច។<br>៤-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖ "ពិធីសារបន្ថែមណាហ្គោយ៉ា-កូឡាឡាំពួរ ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព"។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២២ | ២៥/០៣/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៥/០៣/១៣<br>ម៉ោង ១០:៣០នាទី | ចូលរួមជាសមាជិក ក្នុងពិធីប្រគល់-ទទួលផែនការគ្រប់គ្រងទេសចរណ៍ រវាងស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធរអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | ២៥/០៣/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | ២៧/០៣/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតសុខាភិបាលលើកទី៣៤ និងការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំលើកទី១១ លើសមិទ្ធផលសុខាភិបាលឆ្នាំ២០១២ ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ច ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ២៦ | ២៨/០៣/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៧ | ២៨/០៣/១៣<br>ម៉ោង ១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតសុខាភិបាលលើកទី៣៤ និងការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំលើកទី១១ លើសមិទ្ធផលសុខាភិបាលឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ២៨ | ២៩/០៣/១៣<br>ម៉ោង ០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងៗទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១២/០៣/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន និងបំពាក់កន្សែងជូនទវកាយរឹទ្ធិ ខេត្តមណ្ឌលគិរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបរិវេណមន្ទីរអប់រំយុវជន និងកីឡា ខេត្តមណ្ឌលគិរី។ |
| ២ | ២៥/០៣/១៣<br>ម៉ោង ១០:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់-ទទួល ផែនការគ្រប់គ្រងទេសចរណ៍ រវាងស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធរអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៨/០៣/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១២ ស្តីពីការតាមដានជាសកលកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ Raffle Le Royal ។ |

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៤/០៣/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ២៥/០៣/១៣<br>ម៉ោង ១០:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់-ទទួល ផែនការគ្រប់គ្រងទេសចរណ៍ រវាងស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធរអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៨/០៣/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១២ ស្តីពីការតាមដានជាសកលកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ Raffle Le Royal ។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ គិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១២/០៣/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន និងបំពាក់កន្សែងជូននវកាយរឹទ្ធិ ខេត្តមណ្ឌលគីរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបរិវេណមន្ទីរអប់រំ យុវជន និងកីឡា ខេត្តមណ្ឌលគីរី។ |
| ២ | ១៤/០៣/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៥/០៣/១៣<br>ម៉ោង ១០:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់-ទទួល ផែនការគ្រប់គ្រងទេសចរណ៍ រវាងស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធរអប្សរា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៨/០៣/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០១២ ស្តីពីការតាមដានជាសកលកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ Raffle Le Royal ។ |